

www.kidsofdestiny.org
Kids of Destiny®
Reaching the Next Generation

## 2.10 ការរំដោះដ៏អស្ចារ្យ ( ភាគ២ )

**និក្ខមនំ ៣-១១, ១២:២៩-៣០, ១៤: ១-៣០, ១៥: ១-១៨**

នៅថ្ងៃមួយ ពេលដែលម៉ូសេកំពុងតែឃ្វាលសត្វរបស់គាត់ គាត់បានឃើញមានអ្វីប្លែកកើតឡើងនៅក្នុងគុម្ពោតមួយ។ អូ! មានអណ្តាតភ្លើងចេញពីវា ប៉ុន្តែវានៅតែឆេះមិនសុះ។ គាត់បានខិតទៅជិតមើល នៅពេលដែលសម្លេងខ្លាំងៗ បានបន្លឺឡើងថា "ម៉ូសេ" ម៉ូសេក៏ភ័យខ្លាច ហើយបានបោះជំហានថយក្រោយ ។ សម្លេងនោះចេញមកពីគុម្ពបន្លា “អញបានឮសម្រែកយំរបស់ប្រជាជនអញ"។ នេះគឺជាសម្លេងរបស់ព្រះអម្ចាស់ ដែលមានបន្ទូលថា “អញបានឃើញទឹកភ្នែករបស់ពួកគេ ហើយបានចុះមកដើម្បីជួយសង្គ្រោះពួកគេ ។ ចូរទៅទូលស្តេចឲ្យដោះលែងប្រជារាស្ត្ររបស់អញ ឲ្យមានសេរីភាពចុះ" ។ លោក ម៉ូសេភ័យខ្លាចយ៉ាងខ្លាំង ប៉ុន្តែព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលមកកាន់លោកថា៖ “អញនៅជាមួយឯង” លោកម៉ូសេចូលទៅគាល់ព្រះរាជា ហើយក៏បានទូលថា៖ “ទូលបង្គំនាំសាររបស់ព្រះអម្ចាស់មក" ។ ស្តេចនេះមិនស្តាប់តាមពាក្យរបស់លោកទេ ប៉ុន្តែ លោកម៉ូសេ នៅតែបន្តទូលទៀត ។ សាររបស់ព្រះអម្ចាស់គឺដូច្នេះ៖ “ចូរអនុញ្ញាតឲ្យប្រជាជនរបស់អញចេញទៅ" ។ ព្រះរាជាក៏តបថា “ហេតុអ្វីបានជាខ្ញុំត្រូវឲ្យពួកគេទៅ? ខ្ញុំនឹងមិនអនុញ្ញាតឱ្យពួកគេទៅទេ” ។ ព្រះទ្រង់បានព្រមានដល់ស្តេច១០ដង ហើយទ្រង់ក៏បានបដិសេធមិនឲ្យប្រជាជនចេញទៅដដែល។ រាល់ពេលដែលស្តេចបដិសេធ ព្រះទ្រង់បានបញ្ជូនគ្រោះមហន្តរាយមកលើដី ដើម្បីបញ្ចុះបញ្ចូលព្រះអង្គឱ្យអនុញ្ញាតឱ្យប្រជាជនចេញទៅ។ ប៉ុន្តែ ទ្រង់ជួយសង្គ្រោះប្រជារាស្ត្ររបស់ទ្រង់ឲ្យរួចផុតពីគ្រោះមហន្តរាយគ្រប់បែបយ៉ាង និងរៀបចំឲ្យពួកគេទទួលមាសប្រាក់ និងសម្លៀកបំពាក់ល្អៗ ដូច្នេះ គេនឹងអាចចាកចេញពីកន្លែងនោះបាន តែភ្លាមៗនោះ ព្រះរាជាបានជ្រាបថាគេកំពុងតែចាកចេញ ព្រះអង្គក៏ចាត់ទាហានរបស់ព្រះអង្គឲ្យទៅភ្លាម ដើម្បីនាំពួកគេត្រឡប់មកវិញជាអ្នកទោស។ ពួកគេបានទៅជាមួយសេះ និងរទេះសេះ ដើម្បីបញ្ឈប់ពួកគេ។ លោកម៉ូសេធ្វើដំណើរជាមួយប្រជាជនទាំងអស់ ហើយពួកគេបានទៅដល់មាត់សមុទ្រ។ នៅពេលពួកគេឃើញទាហានទៅដល់ ពួកគេមានការភ័យខ្លាចជាខ្លាំង ប៉ុន្តែលោកម៉ូសេបានជម្រាបថា “កុំខ្លាចអី។ ព្រះអម្ចាស់នឹងច្បាំងជំនួសអ្នកទាំងអស់គ្នា ហើយអ្នកនឹងមិនឃើញស្តេច និងកងទ័ពរបស់ទ្រង់ទៀតឡើយ។ បន្ទាប់មកព្រះអម្ចាស់បានប្រាប់លោកម៉ូសេថា “ចូរលើកដំបងរបស់ឯងឡើង! លាតដៃរបស់អ្នកលើសមុទ្រ។ ញែកទឹកដើម្បីឲ្យប្រជាជនរបស់អញ អាចដើរលើដីស្ងួតបាន”។ លោកម៉ូសេក៏បានធ្វើដូច្នោះ ខ្យល់បក់បោកយ៉ាងខ្លាំងដែលធ្វើឲ្យទឹកសមុទ្របែកជាពីរផ្នែក ។ ប្រជាជនទាំងអស់បានឆ្លងកាត់ដោយសុវត្ថិភាព នៅលើដីស្ងួតរវាងជញ្ជាំងទឹក។ នៅពេលដែលកងទ័ពរបស់ស្តេចបានចាប់ផ្តើមដើរតាមពួកគេឆ្លងកាត់សមុទ្រ ពេលនោះជញ្ជាំងទឹកទាំងសងខាងបានចូលគ្នាវិញ ហើយទាហានទាំងអស់ត្រូវបានលេប។ តាមរបៀបនេះ ព្រះអម្ចាស់បានជួយសង្គ្រោះប្រជារាស្ត្ររបស់ព្រះអង្គ និងដោះលែងពួកគេពីទាសភាពរបស់ស្តេច ។ បន្ទាប់មកលោកម៉ូសេ និងប្រជាជនបានច្រៀងចម្រៀងសរសើរតម្កើងព្រះអម្ចាស់ថា “ព្រះអម្ចាស់ជាកម្លាំង និងចម្រៀរបស់ខ្ញុំ។ ព្រះអង្គបានក្លាយជាសេចក្តីសង្គ្រោះរបស់ខ្ញុំ។ **ភីលីព ២: ១០-១១** ដើម្បីឲ្យអ្វីៗទាំងអស់ ទាំងនៅស្ថានបរមសុខទាំងនៅលើផែនដី ទាំងនៅក្រោមដីនាំគ្នាក្រាបថ្វាយបង្គំ នៅពេលណាឮព្រះនាមព្រះយេស៊ូវ និងឲ្យមនុស្សគ្រប់ភាសាប្រកាសឡើងថា ព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់ ដើម្បីលើកតម្កើងសិរីរុងរឿងនៃព្រះអម្ចាស់ដ៏ជាព្រះវរបិតា ។

## 2.10 ការរំដោះដ៏អស្ចារ្យ ភាគ២ - សេចក្តីណែនាំសម្រាប់គ្រូបង្រៀន

**កំណត់សំគាល់**:

1. ថ្ងៃមួយ ពេលដែលលោកម៉ូសេកំពុងមើលថែហ្វូងសត្វ គាត់បានឃើញអណ្តាតភ្លើងចេញពីគុម្ពបន្លា តែឆេះមិនសុះសោះ ។
2. ព្រះអម្ចាស់ទ្រង់គង់នៅក្នុងគុម្ពបន្លានោះ ។ ទ្រង់មានសារសំខាន់សម្រាប់លោកម៉ូសេ ។ ព្រះទ្រង់ចាត់លោក ម៉ូសេឲ្យទៅរំដោះប្រជារាស្ត្រ ដែលជាទាសកររបស់ស្តេច ។
3. លោកម៉ូសេទៅជួបស្តេច ហើយទូលប្រាប់ទ្រង់ថា ព្រះអម្ចាស់មានព្រះបន្ទូលថា ចូរឲ្យប្រជារាស្ត្រអញចេញទៅ តែស្តេចមិនស្តាប់ឡើយ ។
4. ព្រះអម្ចាស់ប្រទានឲ្យស្តេច នូវគ្រោះកាចទាំងដប់ ។ ពេលនោះយូរណាស់ទាំរាំស្តេចអនុញ្ញាតឲ្យប្រជាជនចេញទៅ ។
5. ប្រជារាស្ត្រចេញទៅបានមួយរយៈពេលខ្លី ស្តេច និងទាហានក៏បានចេញទៅតាមពួកគេ ដើម្បីនាំគេមកវិញ ។ លោកម៉ូសេបាននាំប្រជាជនទៅដល់មាត់សមុទ្រ ។ ពេលទាហានមកជិតដល់ លោកម៉ូសេបានធ្វើតាមព្រះ អម្ចាស់ ។ ព្រះទ្រង់ប្រាប់លោកម៉ូសេ ឲ្យលើកដំបងដាក់លើសមុទ្រ ។ ពេលគាត់ធ្វើតាម ខ្យល់ដ៏ខ្លាំងបក់មកហើយញែកទឹកសមុទ្រជាពីរ ហើយប្រជាជនឆ្លងទៅត្រើយម្ខាង ។
6. ពេលដែលទាហានចាប់ផ្តើមឆ្លងសមុទ្រ ព្រះទ្រង់ឲ្យទឹកត្រឡប់មកដូចដើមវិញ ហើយក៏គ្របពីលើពួកគេទៅ នេះគឺជារបៀបដែលព្រះទ្រង់សង្គ្រោះ ប្រជារាស្ត្ររបស់ទ្រង់ ។ ពេលនោះ លោកម៉ូសេ និងប្រជាជនបានច្រៀងចម្រៀងសរសើរដល់ព្រះអម្ចាស់ ។

**សំណួរ**

១) តើលោកម៉ូសេបានប្រទះឃើញអ្វី ពេលដែលគាត់កំពុងមើលថែហ្វូងសត្វរបស់គាត់?

២) តើព្រះទ្រង់ចាត់លោកម៉ូសេឲ្យធ្វើអ្វី?

៣) តើព្រះទ្រង់ឲ្យលោកម៉ូសេនិយាយអ្វីទៅស្តេច?

៤) តើមានអ្វីកើតឡើង ទើបស្តេចអនុញ្ញាតឲ្យប្រជាជនចេញទៅ?

៥) តើព្រះទ្រង់សង្គ្រោះប្រជារាស្ត្ររបស់ទ្រង់យ៉ាងដូចម្តេច?

**ចម្លើយ**

១) លោកម៉ូសេបានឃើញអណ្តាតភ្លើងចេញពីគុម្ពបន្លា ។

២) ព្រះអម្ចាស់ចាត់ឲ្យលោកម៉ូសេ ទៅរំដោះប្រជារាស្ត្រទ្រង់ពីស្តេច ។

៣) ព្រះទ្រង់ឲ្យលោកម៉ូសេទូលប្រាប់ស្តេចថា ចូរឲ្យប្រជារាស្ត្រយើងចេញទៅ ។

៤) ពេលប្រជាជនចេញទៅ ស្តេចក៏ឲ្យទាហានចេញទៅតាមនាំពួកគេមកវិញ ។

5) ព្រះអម្ចាស់បានធ្វើឲ្យមានផ្លូវដើរ នៅកណ្តាលសមុទ្រ ដើម្បីឲ្យប្រជាជនឆ្លងកាត់ ហើយពេលទាហានឆ្លងតាមព្រះក៏ឲ្យទឹកត្រលប់ដូចដើមគ្របពីលើពួកគេតែម្តង ។ នេះជារបៀបដែលព្រះសង្គ្រោះប្រជារាស្ត្ររបស់ទ្រង់ ។

Kids of Destiny®
Reaching the Next Generation



www.kidsofdestiny.org